## អំពីការកំណត់និយមន័យនៃការបដិសេធន៍ និងបំផ្លែងទ្រង់ទ្រាយHolocaust ដោយសម្ព័ន្ធចងចាំHolocaustអន្តរជាតិ（IHRA）

**សមាជិកនៃសម្ព័ន្ធចងចាំHolocaustអន្តរជាតិ（IHRA）ចំនួន៣១ប្រទេស បានយល់ព្រមកំណត់យកអត្ថន័យស្ដីពីការបដិសេធន៍ និងបំផ្លែងទ្រង់ទ្រាយ នៅក្នុងសម័យប្រជុំអង្គរបស់សម្ព័ន្ធ IHRA នាទីក្រុងតូរ៉ង់តូ នៅថ្ងៃទី១០ ខែតុលា ឆ្នាំ២០១៣ ។**

ការឲ្យនិយមន័យនេះ បានបង្កើតឡើងដោយក្រុមអ្នកជំនាញរបស់សម្ព័ន្ធ IHRA នៅក្នុងគណៈកម្មាធិការស្ដីពីលទ្ធិប្រឆាំងនឹងជនជាតិជ្វីហ្វ និងការបដិសេធន៍Holocaust ដោយមានការសហការជាមួយនឹងតំណាងរដ្ឋាភិបាលនៃប្រទេសជាសមាជិក ដើម្បីប្រើជាឧបករណ៍កំណត់អត្ថន័យ ។

## ការឲ្យនិយមន័យនៃការបំផ្លែងទ្រង់ទ្រាយ និងបដិសេធអំពីHolocaust

និយមន័យដែលកំណត់ឡើងនេះ គឺជាការបង្ហាញឲ្យដឹងថាការបដិសេធន៍ និងបំផ្លែងទ្រង់ទ្រាយHolocaust ត្រូវតែជំទាស់ប្រឆាំងក្នុងកម្រិតជាតិ និងអន្តរជាតិ និងទាមទារការពិនិត្យសិក្សាជាលក្ខណៈសកល ។ ក្នុងន័យនេះ សម្ព័ន្ធ IHRA កំណត់អត្ថន័យនៃកន្សោមពាក្យជានិយមន័យសម្រាប់ការប្រើប្រាស់ជាឧបករណ៍ក្នុងការអនុវត្តន៍ប្រតិបត្តិការ ដោយមិនពាក់ព័ន្ធនឹងផ្លូវច្បាប់ ។

ការបដិសេធន៍អំពីHolocaust គឺជាការនិយាយ និងឃោសនាដែលបដិសេធនឹងការពិតជាប្រវត្តិសាស្ត្រ និងបដិសេធចំពោះការប្រល័យពូជសាសន៍ជនជាតិជ្វីហ្វ ដោយពួកណាហ្ស៊ី និងអ្នកសមគំនិត នៅក្នុងអំឡុងសង្គ្រាមលោកលើកទី២ ដែលហៅថា Holocaust ឬ Shoah ។ ការបដិសេធន៍អំពីHolocaust សំដៅជាក់លាក់ទៅលើការប៉ុនប៉ងណាមួយ ដែលអះអាងថា Holocaust/Shoah មិនបានកើតឡើង ។

ការបដិសេធន៍អំពីHolocaust អាចមានជាការបដិសេធន៍ជាសាធារណៈ ឬជាការបង្កមន្ទិលចំពោះការប្រើវិធីបំផ្លិចបំផ្លាញ (ដូចជា បន្ទប់ឧស្ម័នពុល ការបាញ់សម្លាប់ជាក្រុម បង្អត់អាហារ និងទារុណកម្ម) ឬចេតនាប្រល័យពូជសាសន៍ជាជាតិជ្វីហ្វ ។

ការបដិសេធន៍អំពីHolocaust ក្នុងទម្រង់ផ្សេងៗ គឺជាការបង្ហាញពីការប្រឆាំងនឹងជនជាតិជ្វីហ្វ ។ ការប៉ុនប៉ងបដិសេធអំពីការប្រល័យពូជសាសន៍លើជនជាតិជ្វីហ្វ គឺជាការព្យាយាមដោះលែងអ្នកលទ្ធិសង្គមជាតិនិយម និងលទ្ធិប្រឆាំងនឹងជនជាតិជ្វីហ្វ ឲ្យរួចពីទោសកំហុស ឬការទទួលខុសត្រូវចំពោះអំពើប្រល័យពូជសាសន៍ទៅលើប្រជាជនជ្វីហ្វ ។ ទម្រង់បដិសេធអំពីHolocaust រួមបញ្ចូលទាំងការបន្ទោសជនជាតិជ្វីហ្វពីការបំផ្លើស ឬបង្កើតShoah ដើម្បីផលប្រយោជន៍នយោបាយ ឬផលប្រយោជន៍ហិរញ្ញវត្ថុ ដែលហាក់ដូច Shoah គឺជាលទ្ធផលពីការឃុបឃិតរៀបចំដោយជនជាតិជ្វីហ្វ ។ ការធ្វើដូច្នេះ គឺជាចេតនាដែលមានគោលដៅដាក់កំហុសឲ្យជនជាតិជ្វីហ្វ និងធ្វើឲ្យលទ្ធិប្រឆាំងជនជាតិជ្វីហ្វ មានលក្ខណៈស្របច្បាប់ម្ដងទៀត ។ ជាញឹកញាប់ គោលដៅនៃការបដិសេធន៍អំពីHolocaust គឺជាការស្តារឲ្យមានឡើងវិញដោយបើកចំហរនូវលទ្ធិប្រឆាំងជនជាតិជ្វីហ្វ និងជំរុញនូវមនោគមវិជ្ជានយោបាយ និងលក្ខខណ្ឌនានាដែលអំណោយផលដល់ការផ្ដើមឲ្យមានព្រឹត្តិការណ៍បដិសេធនោះ ។

### ការបំផ្លែងអំពីHolocaust សំដៅលើ ៖

**១) ការព្យាយាមប៉ុនប៉ងដោះសារ ឬសម្រាលផលប៉ះពាល់នៃHolocaust ឬធាតុសំខាន់ៗ ដែលមានអ្នកចូលរួមសហការ និងសម្ព័ន្ធមិត្តរបស់ណាហ្ស៊ីអាល្លឺម៉ង់ ។**

**២) ការបន្ថយចំនួនអ្នករងគ្រោះដោយHolocaust ទាំងអស់ ដែលផ្ទុយខុសពីចំនួនដែលមានប្រភពត្រឹមត្រូវ ។**

**៣) ការប៉ុនប៉ងទិះទៀនបន្ទោសជនជាតិជ្វីហ្វថាជាអ្នកបង្កឲ្យមានអំពើប្រល័យពូជសាសន៍ដោយខ្លួនឯង ។**

**៤) សេចក្ដីថ្លែងការណ៍ដែលយល់ថាHolocaust ជាព្រឹត្តិការណ៍ប្រវត្តិសាស្ត្រវិជ្ជមានមួយ ។ សេចក្ដីថ្លែងការណ៍ទាំងនេះមិនមែនជាការបដិសេធន៍អំពីHolocaust ទេ ប៉ុន្តែជាប់ទាក់ទងខ្លាំងតាមទម្រង់ជាឬសគល់នៃលទ្ធិប្រឆាំងនឹងជនជាតិជ្វីហ្វ ដែលអាចនិយាយថា Holocaustមិនបានឈានទៅដល់ថ្នាក់ សម្រេចតាមគោលដៅគម្រោង «ដំណោះស្រាយចុងក្រោយពីបញ្ហាជនជាតិជ្វីហ្វ» នោះទេ ។**

**៥) ការប៉ុនប៉ងបិទបាំងការទទួលខុសត្រូវលើការបង្កើតជំរុំប្រមូលផ្តុំ និងជំរុំមរណៈ ដែលរៀបចំគ្រប់គ្រង និងប្រតិបត្តិដោយណាហ្ស៊ីអាល្លឺម៉ង់ ដោយដាក់កំហុសទៅលើជាតិសាសន៍ ឬក្រុមជាតិពន្ធុដទៃ ។**

@NEVER AGAIN Association, www.HolocaustEducation-Asia.org, www.NeverAgainAssociation.org